**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**លេខ: ៣៩០ ...ឈ.ហវ.ប្រក**

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពីការកែសម្រួល ការប្រមូល ការបែងចែកប្រាក់ឧបត្ថម្ភ និងការបង់ចូលថវិការដ្ឋ នូវចំណូលពីការផាកពិន័យអន្តរការណ៍ លើករណីល្មើសច្បាប់ចរាចរណ៍ផ្លូវគោក

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញប្រកាសអន្តរក្រសួងលេខ ៣០៩៥ ប្រក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការពិន័យអន្តរការណ៍លើករណីល្មើសច្បាប់ចរាចរណ៍ផ្លូវគោកមានលក្ខណៈជាបទលហុ

-បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដក ៥០% សំរាប់អង្គភាពប្រតិបត្តិការ និងភ្នាក់ងារប៉ូលីសចរាចរណ៍ លើ លិខិតលេខ ២៤៦២ សហវ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** : ប្រាក់ចំណូលដែលបានពីការផាកពិន័យ អន្តរការណ៍នៃបទល្មើសចរាចរណ៍ ដែលមានលក្ខណៈជាបទលហុ ត្រូវបានប្រមូលដោយនគរបាលចរាចរណ៍ផ្លូវគោក នៅតាមគោលដៅ ឬនៅតាមការិយាល័យ នគរបាលចរាចរណ៍នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឬនាយកដ្ឋានសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ។

**ប្រការ២** : ត្រូវបានបង្កើតរដ្ឋទេយ្យករចំណូលនៅការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងនាយកដ្ឋានសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ ដែលត្រូវតែងតាំងដោយប្រកាសអន្តរក្រសួង (ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

**ប្រការ៣** : ចំណូលពីការផាកពិន័យអន្តរការណ៍នៃបទល្មើសចរាចរណ៍ ត្រូវបានបែងចែកជាប្រាក់រង្វាន់ និងជាប្រាក់ ត្រូវបង់ ចូលថវិការដ្ឋ ដូចតទៅ :

-៨០% (ប៉ែតសិបភាគរយ) សំរាប់ជាប្រាក់រង្វាន់លើកទឹកចិត្តដល់អង្គភាពប្រតិបត្តិការ និងនគរបាលចរាចរណ៍ផ្លូវគោកអនុវត្តផ្ទាល់

-២០% (ម្ភៃភាគរយ) សំរាប់ជាប្រាក់បង់ចូលថវិការដ្ឋ។

**ប្រការ៤** : ប្រាក់ចំនួន ៨០% សំរាប់ជារង្វាន់លើកទឹកចិត្ត ត្រូវបែងចែកតាមមុខសញ្ញាដូចខាងក្រោម :

+៥០% ត្រូវបានលើកទឹកចិត្តផ្តល់ឱ្យនគរបាលចរាចរណ៍ផ្លូវគោក ដែលបានបំពេញភារកិច្ចនៅនឹងកន្លែង

+១៥% ត្រូវបានផ្តល់ឱ្យនាយកដ្ឋានសណ្តាប់ធ្នាប់ នៃក្រសួងមហាផ្ទៃ

+១០% ត្រូវបានផ្តល់ឱ្យការិយាល័យចរាចរណ៍ ផ្លូវគោកនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

+៥% ត្រូវបានផ្តល់ឱ្យផ្នែកសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកនៃអធិការដ្ឋាននគរបាល ក្រុង-ស្រុក-ខណ្ឌ។

**ប្រការ៥** : ប្រាក់ចំនួន ២០% សំរាប់បង់ចូលថវិការដ្ឋ ត្រូវអនុវត្តស្របតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ផ្អែកតាមលិខិតបទដ្ឋាននានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៦** :នាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយនាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែកសន្តិសុខរបស់ក្រសួងមហាផ្ទៃ ដើម្បីណែនាំអនុវត្តដល់រដ្ឋទេយ្យករចំណូលនូវការប្រើប្រាស់បង្កាន់ដៃ និងសៀវភៅទិន្នានុប្បវត្តិក្នុងការកត់ត្រាចំណូលប្រចាំថ្ងៃ ។

**ប្រការ៧** :ប្រកាសលេខ ០៩៦ ប្រក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ស្តីពីការប្រមូល ការបែងចែកប្រាក់រង្វាន់ និងការបង់ចូលថវិការដ្ឋ នូវចំណូលពីការផាកពិន័យអន្តរការណ៍ លើករណីល្មើសច្បាប់ចរាចរណ៍ផ្លូវគោក និងលិខិតបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨ ៖** អគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានសណ្តាប់ធ្នាប់ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**